THE SCHOOL DISTRICT OF PHILADELPHIA

**ការិយាល័យ អគ្គនាយក**
440 North Broad Street
Philadelphia, PA 1913

**William R. Hite, Jr., Ed.D.**
អគ្គនាយក

ថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០២០

ជូនចំពោះក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ថ្ងៃអង្គារក្រោយ ថ្ងៃទី ៣ ខែវិច្ឆិកា គឺជាថ្ងៃបោះឆ្នោត។ សាលានឹងបិទសម្រាប់សិស្សានុសិស្សទាំងអស់ ហើយប្រទេសរបស់យើងនឹងចូលរួមក្នុងដំណើរការប្រជាធិបតេយ្យនៃការជ្រើសរើសអនាគតអ្នកដឹកនាំរបស់ខ្លួន។ រដូវកាលនៃការបោះឆ្នោតនេះមានការបែកបាក់គ្នាយ៉ាងខ្លាំង វាបានបន្ថែមលើ ការថប់បារម្ភ និង ភាពតានតឹង ដែលយើងទាំងអស់គ្នាកំពុងដោះស្រាយដោយសារបញ្ហាមេរោគ ខូវីដ-១៩ និង របួសផ្លូវចិត្តផ្សេងៗទៀត។ ក្នុងនាមជាក្រសួងអប់រំ គឺជាការសំខាន់ណាស់ដែលយើងជួយផ្សះផ្សានូវការបែកបាក់ទាំងនេះ  ដោយការគាំទ្រនូវ វប្បធម៌នៃសមភាព ការរួមបញ្ចូល និង ការគោរព ចំពោះ សិស្សានុសិស្ស ក្រុមគ្រួសារ និង បុគ្គលិក ទាំងអស់។

ក្រសួងអប់រំរបស់យើងតំណាងឱ្យភាពចម្រុះនៃប្រទេសអាមេរិច - ភាពចម្រុះនៃ ភេទ ពូជសាសន៍ សាសនា ស្ថានភាព សង្គម-សេដ្ឋកិច្ច សមត្ថភាព ទំនោរនៃក្តីស្រឡាញ់ និង អ្វីៗជាច្រើនទៀត។ យើងម្នាក់ៗនឹងមានប្រតិកម្មខុសៗគ្នាចំពោះការបោះឆ្នោត ដោយផ្អែកលើ អត្តសញ្ញាណ និង គុណតម្លៃរបស់យើង។ ក៏ប៉ុន្តែ មិនថាលទ្ធផលនៃការបោះឆ្នោតនឹងទៅជាយ៉ាងណានោះទេ សាលា និង ការិយាល័យ របស់យើង ត្រូវតែជាទីជម្រកដែលមានសុវត្ថិភាព--ដោយគ្មាន ការស្អប់ ការសម្លុតធ្វើបាប និង ការភ័យខ្លាច។

យើងទាំងអស់គ្នាមានការទទួលខុសត្រូវក្នុងការជួយគ្នាឱ្យមានអារម្មណ៍ថាមាន សុវត្ថិភាព និង មានតម្លៃ។ គឺជាការសំខាន់ណាស់ដែលអ្នកអប់រំរបស់យើងបង្កើតទីកន្លែងដែលការពារសុខុមាលភាពរបស់សិស្សានុសិស្សដែលអាចមានអារម្មណ៍ថាមានហានិភ័យ និង ដឹកនាំការពិភាក្សានៅក្នុងថ្នាក់រៀនដែលសមស្របទៅតាមអាយុ និងមិនលម្អៀង ដែលអនុញ្ញាតឱ្យសិស្សានុសិស្សបង្ហាញពីទស្សនៈរបស់ខ្លួនតាមវិធីត្រឹមត្រូវ។ ហើយវាមានសារៈសំខាន់ណាស់ ដែលយើងទាំងអស់គ្នាយកគំរូតាមវិធីប្រាស្រ័យទាក់ទងជាមួយមនុស្សដែលមានទស្សនៈខុសៗគ្នាដោយ សន្តិភាព និង មានការអត់ធ្មត់។ នេះគឺជាប្រភពជំនួយដែលមានប្រយោជន៍មួយចំនួន ដែលយើងទាំងអស់គ្នាអាចប្រើ៖

- វិធីនិយាយជាមួយ កុមារ និង យុវវ័យ អំពីការបោះឆ្នោត
- វិធីងាយស្រួល ៥ យ៉ាង ដើម្បីនិយាយជាមួយក្មេងអំពីការបោះឆ្នោត
- ការប្រើប្រាស់ការបោះឆ្នោតជាឧបករណ៍សម្រាប់ការបង្ហាត់បង្រៀន

ការនិយាយដោយ ការស្អប់ ការយាយី និង ការរើសអើង ដែលមិនផ្តល់តម្លៃដល់អ្នកដទៃ សិស្សានុសិស្ស និង បុគ្គលិក គ្រប់ទីកន្លែងនៅក្នុងក្រសួងរបស់យើង មិនអាចទទួលយកបានទេ។ បើសិនជាលោកអ្នក ឃើញ ដឹងថា ឬ ជាគោលដៅនៃអាកប្បកិរិយាទាំងនេះ លោកអ្នកអាចរាយការណ៍ ដោយទូរស័ព្ទទៅខ្សែទូរស័ព្ទសំខាន់សម្រាប់ការសម្លុតធ្វើបាបលេខ 1-215-400-៧២៣៣ ឬ ដោយដាក់ពាក្យបណ្តឹងតាមរយៈលិខិតដែលអាចរកបាននៅទីនេះ។

ជាការរំឭក នៅថ្ងៃបោះឆ្នោត អាគារសាលាទាំងអស់ (លើកលែងតែកន្លែងសម្រាប់បោះឆ្នោត) និង មជ្ឈមណ្ឌលផ្តល់ជំនួយបច្ចេកវិទ្យា កុំព្យូទ័រក្រុមប៊ុកទាំងអស់ នឹងត្រូវបិទ។ ការិយាល័យរដ្ឋបាលរបស់យើងនឹងនៅបើកធ្វើការដដែល។

សូមអរគុណចំពោះការចូលរួមចំណែករបស់លោកអ្នកក្នុងការគាំទ្របរិយាកាសដែល ស្វាគមន៍ និង រួមបញ្ចូល សម្រាប់អ្នករាល់គ្នា។ សូមថែរក្សាខ្លួន រក្សាសុវត្ថិភាព និង ចងចាំទៅបោះឆ្នោត! សំឡេងរបស់លោកអ្នកសំខាន់។

ដោយសេចក្តីគោរពរាប់អាន

William R. Hite Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា